ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រុមហ៊ុន ចក-ជេ ដាប់បែលយូ ហ្គាមេន (ខេមបូឌា) ខូអិលធីឌី

## កិច្ចព្រមព្រៀង

រវាង

ក្រុមហ៊ុន ចក-ជេ ដាប់បែលយូ ហ្គាមេន (ខេមបូឌា) ខូអិលធីឌីជាមួយតំណាងកម្មករ និងសហជីពប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃ ខែឧសភា ថ្ងៃទី០៤ វេលាម៉ោង១០និង០០នាទីព្រឹកនៅការិយាល័យរដ្ឋបាលរបស់ក្រុមហ៊ុន ចក-ជេ ដាប់បែលយូ ហ្គាមេន (ខេមបូឌា) ខូអិលធីឌី មានកិច្ចប្រជុំពិភាក្សាមួយរវាងតំណាងក្រុមហ៊ុនជាមួយប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីពដើម្បីកម្មករ ប្រចាំរោងចក្រ។ ក្រោយពីបានប្រជុំពិភាក្សា ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១- ភាគីទាំងពីរយល់ព្រមព្យួរកិច្ចសន្យាការងាររយៈពេល២៧ថ្ងៃចំពោះកម្មករ និយោជិតចំនួន ៨៥នាក់ មានផ្នែកគ្រប់ផ្នែកទាំងអស់ក្នុងរោងចក្រ ដោយគិតចាប់ពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០ ដោយសារគ្មានការបញ្ជាទិញ។

២-ភាគីកម្មករ និយោជិតយល់ព្រមទទួលប្រាក់ឧបត្ថម្ភចំនួន៣០ដុល្លាអាមេរិចក្នុងមួយខែពីក្រុមហ៊ុន និង ៤០ដុល្លាអាមេរិចពីរាជរដ្ឋាភិបាល។

៣-ក្រុមហ៊ុននិងបើកប្រាក់ឧបត្ថម្ភ៣០ដុល្លាអាមេរិចជូនកម្មករ និយោជិត១ខែម្តង។

៤-បងប្អូនកម្មករ និយោជិតត្រូវត្រលប់ចូលធ្វើការវិញនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ក្នុងករណីបងប្អូនកម្មករ និយោជិតមិនបានចូលធ្វើការវិញតាមកាលកំណត់នោះទេ ក្រុមហ៊ុននិងអនុវត្តតាមច្បាប់ស្តីពីការងារ និងតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតៅទៅ។

ថ្ងៃច័ន្ទ ១៣កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣

ភ្នំពេញថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

ស្នាមមេដៃតំណាងកម្មករ និងសហជីព

តំណាងក្រុមហ៊ុន

JOC-J & W GARMENT (CAMBODIA) Co., Ltd.